សាលារៀនទន្សាយ/Rabbit School

Address: # National Borey Infant and Child , St Doung Ngiep II, Phum Doum Nakthom ,
Sangkat Stung Meanchay, Khan Mean Chay, Phnom Penh,Cambodia.
Phone: (855) 12369376, 086 948 811, 093 851 047 Email: huntouch40@gmail.com,
Website: www.rabbitschoolcambodia.net

# កម្រងមតិយោបល់របស់ភាគីពាក់ព័ន្ធពីវេទិកាថ្នាក់ក្រោមជាតិ
# នៅភ្នំពេញ កណ្ដាល កំពង់ស្ពឺ និងសៀមរាប ឆ្នាំ ២០១៨
# សរុបអ្នកចូលរួម៖ ១៩៩ នាក់ (ស៖១៣២ នាក់)

## ថ្នាក់ក្រោមជាតិផ្នែកវិស័យអប់រំ: ៣៨ នាក់ (ស៖១៦ នាក់) (មន្ទីរអប់រំ,ការិយាល័យអប់រំ,នាយកសាលា)

1. ផលវិបាកក្នុងការបញ្ចូលផែនការអភិវឌ្ឍកុមារពិការក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់ តាមច្បាប់កិច្ចការពារ និង លើកកម្ពស់សិទ្ធិជនពិការ និង គោលនយោបាយអប់រំបរិយាប័ន្ន
   - 1.1. គ្មានអង្គការដៃគូគាំទ្រនៅពេលធ្វើសមារណកម្មផែនការនៅថ្នាក់ស្រុក
   - 1.2. ផលលំបាកក្នុងការបញ្ចូលផែនការអភិវឌ្ឍកុមារពិការទៅក្នុងសាលារៀនតាមផែនការអភិវឌ្ឍសាលារៀនតាមគោលការណ៍គោលនយោបាយបរិយាបន្ន
   - 1.3. ផ្សព្វផ្សាយគោលនយោបាយអប់រំកុមារពិការដល់គ្រប់តំបន់នៅមានកម្រិត
   - 1.4. ពិបាកក្នុងការកំណត់អត្តសញ្ញាណកុមារពិការ( ឧបករណ៍ និងជំនាញ, ខ្វះការចូលរួមពីឪពុកម្ដាយ៎ ខ្វះកិច្ចអន្តរាគមន៍ )
   - 1.5. ខ្វះថវិកាគាំទ្រកិច្ចដំណើរការផែនការអភិវឌ្ឍកុមារពិការ
   - 1.6. ប្រមូលកុមារពិការចូលរៀនមិនទាន់អស់និងបន្តការរៀនឱ្យនៅគង់វង្ស
   - 1.7. គ្រូបង្រៀន/នាយក កុមារពិការមិនមានជំនាញច្បាស់លាស់ (គ ថ្លង់ សតិបញ្ញា )
   - 1.8. ការយល់ដឹងនៅមានកម្រិតនិងខ្វះការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ
   - 1.9. ឱកាសនិងពេលវេលាមិនគ្រប់គ្រាន់សម្រាប់កុមារពិការ
   - 1.10. ផលប្រយោជន៍ដែលកុមារទទួលមិនដូចគ្នាស្មើគ្នា
   - 1.11. នៅមានការរើសអើងចំពោះកុមារពិការក្នុងការចូលរួមសកម្មភាពនានានិងការស្វែងរកសេវា
   - 1.12. ខ្វះធនធានមនុស្សផ្នែកពិការភាព

## ក្រុមគ្រូបង្រៀនកុមារពិការ៖៤៧ នាក់( ស៖៣០នាក់ )

2. តើអ្នកមានផលលំបាកអ្វីខ្លះក្នុងការផ្ដល់សេវាអប់រំកុមារពិការ ?
   - 2.1. កុមារមានការលំបាកទាំងបញ្ញា និងអកប្បកិរិយា,មានភាពរពិសខ្លះ កុមាមានការភ្លេចភ្លាំងច្រើន ពិបាកក្នុងការផ្ទង់អារម្មណ៍, ពិបាកក្នុងការទំនាក់ទំនងគ្នាជាមួយមិត្តភក្រនិងគ្រូបង្រៀន, កុមារអាចបង្កគ្រោះថ្នាក់ដល់ខ្លួនឯងនិងអ្នកដទៃ
   - 2.2. គ្រូបង្រៀនមានចំណេះដឹងនៅមានកម្រិត, គ្រូពិបាកក្នុងការបង្រៀនជាងបង្រៀនកុមារធម្មតា

**ក្រុមអង្គាធរថ្នាក់ក្រោមជាតិ: ៣៩ នាក់ (សៈ ២៥ នាក់) (មន្ទីរសង្គមកិច្ច, សង្គមកិច្ចស្រុក, អង្គាធរស្រុក,មេឃុំ)**

3. ផលវិបាកក្នុងការបញ្ចូលផែនការអភិវឌ្ឍកុមារពិការក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់ តាមច្បាប់កិច្ចការពារ និង លើកកម្ពស់សិទ្ធិជនពិការ និង គោលនយោបាយអប់រំបរិយាប័ន្ន

3.1. អត់ខ្ទង់ថវិកាសម្រាប់ចំណាយឬថវិកានៅថ្នាក់ឃុំ សង្កាត់ សម្រាប់គាំទ្រកុមារពិការមានចំនួនតិច

3.2. ខ្វះការចូលរួមពីស្ថាប័នពាក់ព័ន្ធនិងសហគមន៍, គ្មានអង្គការដៃគូគាំទ្រផ្នែកពិការភាពនៅពេលធ្វើសមារណកម្មផែនការនៅថ្នាក់ស្រុក

3.3. ការយល់ដឹងអាណាព្យាបាលកុមារពិការ/ជនពិការនៅមានកម្រិត

3.4. មានការលំបាកក្នុងការប្រមូលទិនន្ន័យកុមារពិការ (ខ្វះការចូលរួមពីឪពុកម្តាយ)

3.5. ការផ្តល់ព័តមានមិនទាន់ពេលវេលា, ខ្វះកិច្ចអន្តរាគមន៍ពីភាគីពាក់ព័ន្ធ

3.6. ការយល់ដឹងរបស់អង្គាធរលើការដាក់ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពនៅមានកម្រិត

3.7. ប្រជាពលរដ្ឋមិនបានលើកឡើងពីបញ្ហាពិការភាពដាក់ក្នុងផែនការ

3.8. ធនធានមនុស្សមិនសមស្របនិងដំណោះស្រាយបញ្ហាពិការភាព

3.9. បានដាក់ចូលផែនការហើយតែមិនមានអ្នកគាំទ្រ

3.10. អង្គាធរស្រុកឃុំ ពុំទាន់យល់ច្បាស់ពីច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ

3.11. ជនពិការពុំសូវបានចូលរួមក្នុងពេលធ្វើផែនការអភិវឌ្ឍ

3.12. ជនពិការនិងក្រុមគ្រួសារមួយចំនួន គាត់ធ្វើចំណាកស្រុក

**ក្រុមអាណាព្យាបាលកុមារពិការៈ ៧៥ នាក់ (សៈ ៦១នាក់)**

4. តើអ្នកមានផលលំបាកអ្វីខ្លះក្នុងការទទួលសេវាពីច្បាប់កិច្ចការពារ និង លើកកម្ពស់សិទ្ធិជនពិការ និង គោលនយោបាយអប់រំបរិយាប័ន្ន?

4.1. កង្វះខាតសាលារៀននិងគ្រូជំនាញ

4.2. សមត្ថភាពគ្រូនៅមានកម្រិត/គ្រូបង្រៀនមានចំណេះដឹងនៅមានកម្រិត

4.3. សាលារៀនមានការខ្វះខាតសម្ភារៈ និងឧបករណ៍ក្នុងការបង្រៀន

4.4. បង្កើតកម្មវិធី/សៀវភៅសម្រាប់បង្រៀនកុមារអូទីសឹម

4.5. ចង់ឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីកុមារខ្សោយសតិបញ្ញា នៅតែមានការរើសអើងនៅក្នុងសាលារៀននិងសហគមន៍ (កុំឱ្យមានការរើសអើងពីមជ្ឈដ្ឋានខាងក្រៅ)

4.6. ធ្វើបណ្ណសម្គាល់/បញ្ជាក់ដល់កុមារពិការ ,អាទិភាពដល់កុមារអូទីសឹម

4.7. ពិបាកពេលកូនឈឺញ៉ាក់ញាប់ សុខភាពទន់ខ្សោយ និងប្រកាច់ញ៉ាក់ញាប់, កង្វះខាត/ពិបាករកសេវាព្យាបាល, ក្រីក្រនិងអត់មានលទ្ធភាពនាំកូនមកសាលារៀន(ភាគច្រើនទៅពេទ្យប្រទេសក្រៅវៀតណាមនិងថៃ)

4.8. ផ្តល់ប្រាក់ឧបត្ថម្ភដល់អ្នកជំនាញ

4.9. បង្កើតសមាគមអាណាព្យាបាលដែលមានកូនមានពិការភាព

4.10. បើកថ្នាក់រៀនអាណាព្យាបាលឱ្យក្លាយជាអ្នកជំនាញសម្រាប់អប់រំកូន

4.11. ផលលំបាកនៅពេលគ្រប់អាយុរកការងារធ្វើ

4.12. ពិបាករកសេវាផ្លូវច្បាប់និងសេវាយុត្តិធ៌មសម្រាប់កុមារពិការ

4.13. ពិបាកធ្វើដំណើរឆ្លងថ្នល់ ខ្វះមធ្យោបាយធ្វើដំណើរក្នុងការបញ្ជូនកូនមកសាលារៀន, មានការបារម្ភណ៍ពីសុវត្ថិរបស់កូន (ខ្លាចគេធ្វើបាបពេលមកសាលារៀន )